# តើលោកអ្នកកំពុងទទួល Parenting Payment (ប្រាក់ជំនួយសំរាប់មាតាបិតា) និងកំពុងធ្វើការឬទេ?



We speak your language ☎ 13 1202

*Are you receiving Parenting Payment and working?* – **Khmer**

## នេះគឺជាចំណុចសំខាន់ខ្លះដែលលោកអ្នកត្រូវពិចារណា

បើប្រាក់ចំណូលរបស់លោកអ្នកឬគូរួមមេត្រីភាពរបស់លោកអ្នកមានការផ្លាស់ប្តូរ លោកអ្នកត្រូវប្រាប់យើងខ្ញុំ:

- **ក្នុងរង្វង់ពេល 14 ថ្ងៃ នៅពេលដែលប្រាក់ចំណូលលោកអ្នកកើនឡើង** បើពុំនោះសោតទេ លោកអ្នកអាចត្រូវបង់សងមកវិញនូវប្រាក់ជំនួយខ្លះ ឬប្រាក់ជំនួយទាំងអស់របស់លោកអ្នក ហើយក៏ប្រហែលជាត្រូវបង់សង ថ្លៃឈ្នួលសំរាប់ការទារសំណាងនៃប្រាក់ជំនួយនេះមកវិញផងដែរ; ឬ
- **ភ្លាមនៅពេលដែលប្រាក់ចំណូលលោកអ្នកចុះថយ** បើពុំនោះសោតទេ លោកអ្នកប្រហែលជាមិនបានទទួលប្រាក់បន្ថែមខ្លះ។

សូមប្រាប់យើងខ្ញុំនូវចំនួន**ប្រាក់មិនទាន់បង់ពន្ធ**ដែលលោកអ្នកទទួល។ នេះគឺជាចំនួនប្រាក់មុនបង់ពន្ធនិងចំនួនកាត់យកចេញផ្សេងៗទៀត។ និយោជកលោកអ្នកអាចប្រាប់លោកអ្នកនូវអត្រាប្រាក់បើកប្រចាំម៉ោងរបស់លោកអ្នក ដោយមានរួមទាំងប្រាក់ឧបត្ថម្ភ ព្រមទាំងអត្រាប្រាក់បើកសំរាប់ថ្ងៃចុងអាទិត្យឬថ្ងៃឈប់សំរាក ឬអត្រាប្រាក់បើកសំរាប់ពេលលើសម៉ោងធ្វើការធម្មតា។

សូមប្រាប់យើងខ្ញុំនូវប្រាក់ចំណូលសំរាប់ថ្ងៃនីមួយៗដែលលោកអ្នកបានធ្វើការ ទោះជាលោកអ្នក មិនទាន់បានទទួលប្រាក់ចំណូលនេះក៏ដោយ។

បើលោកអ្នកឬគូរួមមេត្រីភាពរបស់លោកអ្នកមាននិយោជកច្រើនជាងម្នាក់ សូមប្រាប់យើងខ្ញុំនូវប្រាក់ចំណូលដែលទទួលពីនិយោជកនីមួយៗ។

លោកអ្នកត្រូវប្រាប់យើងខ្ញុំ បើលោកអ្នកឬគូរួមមេត្រីភារបស់លោកអ្នកទទួលប្រាក់បំណាច់បន្ថែមណាមួយពីនិយោជករបស់លោកអ្នក ឬពីប្រភពណាមួយផ្សេងទៀត (ឧទាហរណ៍: ការប្រើប្រាស់រថយន្តជាផ្នែកនៃសំណុំបៀវត្សរ៍របស់លោកអ្នក)។

សូមប្រាប់យើងខ្ញុំ បើចំនួនម៉ោងធ្វើការរបស់លោកអ្នកមានការផ្លាស់ប្តូរ។

លោកអ្នកក៏ត្រូវប្រាប់យើងខ្ញុំផងដែរអំពីប្រាក់ចំណូលរបស់លោកអ្នកឬគូរួមមេត្រីភាពរបស់លោកអ្នក នៅលើក្រដាសពិនិត្យឡើងវិញ បើយើងខ្ញុំតំរូវឲ្យលោកអ្នកបំពេញនិងប្រគល់ក្រដាសនេះមកវិញ។ យើងខ្ញុំត្រូវការឆែកមើលប័ណ្ណជូនដំណឹងអំពីប្រាក់ចំណូល ឬលិខិតពីនិយោជកលោកអ្នក ដែលបង្ហាញចំនួនប្រាក់ដែលលោកអ្នកបានទទួល ក្នុងអម្លុងពេលដែលតំរូវដោយក្រដាសពិនិត្យឡើងវិញនេះ។

សុំយក Casual Income Record (បញ្ជីកត់ត្រាប្រាក់ចំណូលម្តងម្កាល) ពីការិយាល័យ Centrelink ណាមួយក៏បានដែរ។ បញ្ជីកត់ត្រានេះអាចជួយលោកអ្នកក្នុងការកត់ត្រាប្រាក់ចំណូលរបស់លោកអ្នក។

## សូមចងចាំ

បើលោកអ្នកកំពុងទទួលប្រាក់ Parenting Payment (ប្រាក់ជំនួយសំរាប់មាតាបិតា) ហើយគូរួមមេត្រីភាពរបស់លោកអ្នកកំពុងទទួល Newstart Allowance (ប្រាក់ជំនួយ Newstart) សូមសរសេរប្រាក់ចំណូលរបស់លោកអ្នកនៅលើក្រដាសពិនិត្យឡើងវិញពេលពីរអាទិត្យម្តងរបស់គូរួមមេត្រីភាពរបស់លោកអ្នកផងដែរ។.

ដើម្បីនិយាយទៅកាន់ Centrelink ជាភាសាខ្មែរ សូមទូរស័ព្ទទៅលេខ **13 1202*** ។
លោកអ្នកក៏អាចរកឃើញព័ត៌មានជាភាសាលោកអ្នក នៅតាមវិបសៃ **www.centrelink.gov.au** ផងដែរ។

** លោកអ្នកអាចប្រើកិច្ចបំរើទូរស័ព្ទស្តង់ដារនៅគ្រប់ទីកន្លែងទាំងអស់ក្នុងរង្វង់ប្រទេសអូស្ត្រាលីដើម្បីទូរស័ព្ទទៅកាន់លេខចាប់ផ្តើមដោយលេខ "13" ដោយបង់ថ្លៃមិនលើសពីថ្លៃទូរស័ព្ទក្នុងតំបន់ឡើយ (ថ្លៃទូរស័ព្ទអាចមានតម្លៃខុសៗគ្នា ដោយអាស្រ័យលើក្រុមហ៊ុនផ្តល់កិច្ចបំរើទូរស័ព្ទ)។ ទូរស័ព្ទទៅលេខចាប់ផ្តើមដោយលេខ "1800" ឥតមានគិតថ្លៃទេ។ ទូរស័ព្ទចេញពីទូរស័ព្ទសាធារណៈដែលត្រូវបង់ប្រាក់ ទូរស័ព្ទចល័ត នឹងត្រូវបង់ថ្លៃតាមអត្រាខ្ពស់ជាងនោះ។*

www.centrelink.gov.au

Australian Government

Centrelink
giving you options